**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**

**សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

លេខ ៣៧៣.១៩.សហវ

ថ្ងៃសុក្រ ១៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៨

**សូមគោរពជូន**

- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
- **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**
- **លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **ឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**កម្មវត្ថុ ៖** សំណើសុំចុះសិក្សាដើម្បីវាយតម្លៃកម្រិតនៃការផ្លាស់ប្តូរលើការប្រើប្រាស់ប្រព័ន្ធ FMIS និង ប្រមូលធាតុចូលបន្ថែមពីអ្នកប្រើប្រាស់ សម្រាប់ជាមូលដ្ឋានក្នុងការកែលម្អដំណើរការ និង ការអនុវត្តប្រព័ន្ធ FMIS ឱ្យកាន់តែប្រសើរ ។

**ជូនភ្ជាប់៖** តារាងកាលវិភាគនៃការចុះសិក្សាតាមក្រសួងសាមី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ក្នុងក្របខណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរ នៅដើមឆ្នាំ២០១៨ មុនពេលដាក់ប្រព័ន្ធ FMIS ឱ្យប្រើប្រាស់នៅក្រសួងទាំង១០ ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានចុះសិក្សាម្តងរួចមកហើយអំពីកម្រិតនៃការត្រៀមខ្លួនក្នុងការផ្លាស់ប្តូររបស់អ្នកប្រើប្រាស់នៃក្រសួងនីមួយៗមុននឹងឈានទៅប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការវិភាគ និង រៀបចំដាក់ប្រព័ន្ធ FMIS ឱ្យប្រើប្រាស់ជាផ្លូវការ ។ ស្របតាមផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញ ក្រុមការងារនឹងត្រូវបន្តអនុវត្តសកម្មភាពចុះសិក្សាដើម្បីវាយតម្លៃកម្រិតនៃការផ្លាស់ប្តូរលើការប្រើប្រាស់ប្រព័ន្ធជាមួយអ្នកដែលកំពុងប្រើប្រាស់ ។ ទន្ទឹមនឹងនេះ ក្រុមការងារនឹងជួបពិភាក្សាផ្ទាល់ជាមួយក្រុមការងារអនុវត្តគម្រោង FMIS នៅតាមក្រសួងសាមីផងដែរ ក្នុងន័យប្រមូលធាតុចូលគន្លឹះៗជាក់ស្តែងបន្ថែម សម្រាប់ជាមូលដ្ឋានក្នុងការវិភាគ និង កែលម្អដំណើរការ និង ការអនុវត្តប្រព័ន្ធ FMIS ឱ្យកាន់តែប្រសើរ និង កាន់តែមានប្រសិទ្ធភាព ។

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ៖ ៨៥៥ ២៣ ៤៣០០៦៣ ទូរសារ៖ ៨៥៥ ២៣ ៤៣០០៦៣
Phone : 855-23-430 063 Fax : 855-23-430 063

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ មេត្តាចាត់ក្រុមការងារអនុវត្តគម្រោង FMIS ប្រចាំក្រសួងសាមី ដើម្បីរៀបចំ និង សម្របសម្រួលឱ្យក្រុមការងារគ្រប់គ្រងគម្រោង FMIS អនុវត្តការងារប្រកបដោយភាពរលូន និងជោគជ័យ ទៅតាមកាលវិភាគដូចបានជូនភ្ជាប់ ។ ក្នុងករណីមានចម្ងល់ ឬត្រូវការព័ត៌មានបន្ថែម សូមទំនាក់ទំនងមក **លោកស្រី ជួន ចាន់ណា** ទទួលបន្ទុកការងារគ្រប់គ្រងការផ្លាស់ប្តូរ តាមរយៈទូរស័ព្ទលេខ ០៩២ ៥៩៥ ៨២០ ឬ ០១៦ ៥១១ ៣៨០ ។

សូម ឯកឧត្តម មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមការងារគ្រប់គ្រងគម្រោង** FMIS

***ចម្លងជូន៖***

- *ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ*
- *អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *ឯកសារ-កាលប្បវត្តិ*

**បណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**

**តារាងកាលវិភាគចុះសិក្សាកម្រិតនៃការផ្លាស់ប្តូរអ្នកដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS របស់ក្រសួងសាមី**

| ល.រ | ក្រសួង | ថ្ងៃខែឆ្នាំ | ពេលវេលា | ផ្សេងៗ |
|---|---|---|---|---|
| ១ | ក្រសួងបរិស្ថាន (រួមទាំងអាណាប័កផ្ទេរសិទ្ធិ) | ១៥ សីហា ២០១៨ | ០៩:០០ ព្រឹក | |
| ២ | ក្រសួងប្រៃសនីយ៍និងគមនាគមន៍ | ១៥ សីហា ២០១៨ | ០២:៣០ រសៀល | |
| ៣ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៦ សីហា ២០១៨ | ០៩:០០ ព្រឹក | |
| ៤ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ១៦ សីហា ២០១៨ | ០២:៣០ រសៀល | |
| ៥ | ក្រសួងមុខងារសាធារណៈ | ១៧ សីហា ២០១៨ | ០៩:០០ ព្រឹក | |
| ៦ | ក្រសួងកិច្ចការនារី | ១៧ សីហា ២០១៨ | ០២:៣០ រសៀល | |
| ៧ | ក្រសួងសុខាភិបាល | ២០ សីហា ២០១៨ | ០៩:០០ ព្រឹក | |
| ៨ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២០ សីហា ២០១៨ | ០២:៣០ រសៀល | |
| ៩ | ក្រសួងអប់រំ យុវជន និងកីឡា | ២១ សីហា ២០១៨ | ០៩:០០ ព្រឹក | |

*សូមទំនាក់ទំនងមកលោកស្រី ជួន ចាន់ណា តាមរយៈលេខទូរស័ព្ទ÷ ០៩២ ៩៩៥ ៨២០/ ០១៦ ៥១១ ៣៨០